# ការសំភាសន៍របស់អ្នកមីង ប្រាក់វាសនា

**កៈ អ្នកសំភាសន៍ឈ្មោះ សួន សុខលី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ប្រាក់ វាសនា**

## ការសង្ខេបរបស់អ្នកមីង ប្រាក់វាសនា

អ្នកមីង ប្រាក់វាសនា គាត់មានអាយុ ៣៩ ឆ្នាំ។ អ្នកមីង ប្រាក់វាសនា មានភេទស្រី។ អ្នកមីង ប្រាក់វាសនា មានទីលំនៅនាពេលបច្ចុប្បន្ននៅ ភូមិប្រព្វាយ៍ ឃុំសែនសុខ សង្កាត់សែនសុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ។ អ្នកមីង ប្រាក់វាសនា មានកូនទាំងអស់ចំនួន៣នាក់ ។ អ្នកមីង ប្រាក់វាសនា បានរៀបអាពាហ៍ពិពាហ៍ នៅឆ្នាំមិនបានប្រាប់ពីឆ្នាំទេ។ អ្នកមីង ប្រាក់វាសនា មានប្ដីចំនួន ១នាក់ មានឈ្មោះ ជា តាំម ជាជនជាតិវៀតណាម។

កៈ ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីង ដែលអនុញ្ញាតអោយខ្ញុំធ្វើការសំភាស៍អំពីជីវប្រវិត្តិរបស់អ្នកមីង។ ហើយកាលសំភាស៍នេះគឺធ្វើឡើងដោយសារតែសលកវិទ្យាល័យ BYU ដោយសារតែសកលវិទ្យាល័យនិងចង់ថៃរក្សារជីវប្រវត្តិជីដូនជីតារបស់អ្នកមីងនិងជីដូនជីតារបស់អ្នកមីង ទុកអោយកូនចៅជំនាន់ក្រោយស្ដាប់ពីសំលេងរបស់មីង ហើយបន្ទាប់ពីការសំភាស៍នេះរួចហើយ តើខ្ញុំអាចសូមដាក់ការសំភាស៍មួយនេះនៅក្នុងប្រព័ន្ធវេបផ្សាយមួយដែលមានឈ្មោះថា www.cambodianoralhistories.byu.edu បានដែរឬទេអ្នកមីង?

ខៈ ចារបាន។

កៈ ចារហាហារ ហើយចឹងខ្ញុំជាអ្នកសំភាស៍អុំមានឈ្មោះថា សួន សុខលី។ ហើយការសំភាស៍នេះធ្វើឡើងនៅថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ២០១៨ ដែលមានទីតាំងនៅអីគេដែលអ្នកមីង?

ខៈ ភូមិប្រព្វាយ៍ ឃុំសែនសុខ សង្កាត់សែនសុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ។

កៈ ហើយខ្ញុំចង់សួរមីងថា តើអ្នកមីងមានឈ្មោះនិងនាមត្រកូន ឈ្មោះអ្វីដែលអ្នកមីង?

ខៈ ចារខ្ញុំមានឈ្មោះថា ប្រាក់វាសនា។

ក៖ ហើយមីងឈ្មោះនិងត្រូវនិងអតសញ្ញាណប័ណ្ណរបស់បឹងដែលតាស់អី?

ខ៖ ចារឈ្មោះនិងត្រូវនិងអតសញ្ញាណប័ណ្ណរបស់មីង មិនដែលផ្លាស់ទេ?

ក៖ ចារហើយមីងមានឈ្មោះហៅក្រៅទៀតទេ?

ខ៖ អត់ អត់សោះតែម្តងតាំងតែពីដើមមក មានតែឈ្មោះមួយនិង ហើយក៏មិនដែលប្តូរឈ្មោះដែល។

ក៖ ចារហើយគេស្គាល់តែឈ្មោះនិងមួយទេ?

ខ៖ មានឈ្មោះមួយនិង គេមិនដែលហៅអីផង?

ក៖ ចារហើយខ្ញុំចង់សួរមីងថា មីងមានអាយុប៉ុន្មានហើយឆ្នាំនេះ?

ខ៖ ខ្ញុំមានអាយុប្រហែល ៣៩ មិនប្រហែលទេ គឺ៣៩ឆ្នាំនិងតែម្តង និងហើយកុំប្រហែលអី គឺ ៣៩ហើយ ហាហារ អាយុ៣៩ ហើយកូន៣ ឆ្នាំមមែ។

ក៖ ចឹងមីងមានឆ្នាំខ្មែរគឺឆ្នាំមមែ?

ខ៖ ឆ្នាំមមែនិងហើយ។

គ៖ អរអាយុស្មើរប្តីខ្ញុំដែល។

ខ៖ ចារបង។

ក៖ ហើយមីងកើតនៅឆ្នាំណា ភូមិអី ឃុំអី នៅស្រុកណាដែលមីង?

ខ៖ ខ្ញុំកើតនៅភូមិព្រៃឈើទៀល ឃុំអង្គរសោម ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។

ក៖ ចារហើយមីងផ្លាស់ប្តូរមកនៅភ្នំពេញនេះយូរហើយឬនៅមីង?

ខ៖ ខ្ញុំមកនៅបាន ១០ឆ្នាំគត់។

ក៖ ចារ ហើយមីងមកនៅទីនេះដើម្បីធ្វើអីគេដែលមីង?

ខ៖ ខ្ញុំមកធ្វើការរោងចក្រ។

ក៖ ចារហើយមីងមកទាំងគ្រួសារឬក៏ម្នាក់ឯង?

ខ៖ ខ្ញុំមកម្នាក់ឯង និងបីនាក់ប្ដូននាក់ម្ដាយកូន មកនិងមកប្ដូននាក់ កូននៅតូចៗ។

ក៖ ចារកូនមីងប្រុសឬក៏ស្រី?

ខ៖ កូនស្រីដំបូង កូនប្រុសកណ្ដាល កូនពៅស្រីតូច នោះនៅតូចមិនទាន់បានធំអីទេ សំរាប់ប្រើប្រាស់ជួយជីវភាព ព្រោះជីវភាពយើងកុំពង់តែទឹងតែង។

ក៖ ចារចឹងមានតែមីងម្នាក់ឯងទេដែលជាជំហារ?

ខ៖ ខ្ញុំធ្វើតែម្នាក់ឯងទេ កូនខ្ញុំក៏មិនបានរៀន ស្ដាយណាស់ ឃើញកូនឯងរៀនសូត្រចឹងជូនពរអោយកូនរីកចំរើន។

ក៖ ចារអរគុណមីង។

ខ៖ មីងនិយាយមែន មនុស្សគ្នាយើង យើងចេះនិយាយគ្នា។

ក៖ ហើយខ្ញុំចង់សួរអ្នកមីងទៀតថា មីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែល?

ខ៖ ខ្ញុំមានបងប្អូនចំនួន ៧ នាក់។

ក៖ ហើយមីងជាកូនទីប៉ុន្មាន?

ខ៖ កូនទី៧ ចុងគេបង្អស់។

ក៖ បាហារ ចឹងមីងអាចរៀបរាប់ឈ្មោះពីកូនបងរហូតដល់កូនពៅបានទេមីង?

ខ៖ ចារបានតាស់ ឈ្មោះបងប្រុសគេបង្អស់និងមានឈ្មោះថា ប្រាក់ ស៊ន រួចមកបងស្រីឈ្មោះ ប្រាក់ សៀង មកដល់បងទីបីឈ្មោះ ប្រាក់ សួន បងទីបួនឈ្មោះ ប្រាក់ ស៊ែរ បងទីប្រាំឈ្មោះ ប្រាក់ ស៊យ និងបងទីប្រាំមួយឈ្មោះ ប្រាក់ សំ រួចខ្ញុំស្រីឈ្មោះ ប្រាក់ វាសនា។ នេះតាំងពីមីកូនខ្ញុំនេះ អាឡូវពោះធំប្រាំបីខែហើយនេះ អង្គុយអានរឿងនិងមើលកូន។

ក៖ កូនមីងពួកគាត់ស្អាតៗមែនទែន។

ខ៖ កូនខ្ញុំមីស្រីនិងស្អាតណាស់ មីស្រីមិញចុះពីលើម៉ូតូនិង។ ខ្ញុំស្តាយណាស់ដែលមិនបានអោយកូនរៀន ឃើញគេជីវិតតស៊ូរ បានរៀនសូត្រ ចំនែកខ្ញុំវិញការមិនពិតប្រកត់ ធ្វើការរោងចក្រ មិនមានលទ្ធភាពអោយកូនរៀន។

ក៖ ហើយខ្ញុំចង់សួរមីងទៀតថា តើមីងបានចង់ចាំអ្វីខ្លះពីបងប្អូនសាច់ញាតិមីងតាំងពីនៅក្មេងណា?

ក៖ កាលខ្ញុំនៅក្មេង ខ្ញុំមានសំណាងណាស់ព្រោះមានបងៗច្រើន ដល់ពេលបងៗគាត់មានប្តីមានប្រពន្ធទៅអស់សល់តែយើង នៅពិបាកម្នាក់ឯង រស់នៅជាមួយឪពុកម្តាយចាស់ទៀត ដល់ពេលចឹងទៅ យើងមិនដឹងថាខ្លួនយើងយ៉ាងមេច ហើយដល់ចឹងទៅខ្ញុំក៏មកធ្វើការរោងចក្រនិងដើម្បីជួយឪពុកម្តាយយើងដែលចាស់ៗនិងណា ព្រោះបងៗអីពេលពួកគាត់មានប្រពន្ធកូនទៅគាត់ក៏មិនបានមកជួយអីយើងចឹងណា គាត់មកដែល មកនៅពេលចូលឆ្នាំខ្មែរអីចឹងទៅណា បុណ្យភ្ជុំអីគាត់មកលេងហើយ តែគាត់មានប្តីមានប្រពន្ធអស់ទៅនៅឆ្ងាយៗពីគ្នាចឹងទៅណា អត់បាននៅជិតខ្លួនយើងនេះទេ តែពេលឪពុកម្តាយអីឈើគាត់ក៏បានមកមើលដែល តែគាត់មានប្រីប្រពន្ធនៅឆ្ងាយៗ តែអាឡូវឪពុកម្តាយខ្ញុំអីពួកគាត់ស្លាប់អស់ហើយ អត់មានអីដែលត្រូវបារម្មណ៏ទៀតទេខ្ញុំ នៅតែខ្ញុំនិងកូនបីនេះ។

ក៖ ចារហើយឪពុកម្តាយរបស់មីងគាត់ស្លាប់តាំងពីពេលឆ្នាំណាដែលមីង?

ខ៖ អើម្តាយខ្ញុំគាត់ស្លាប់តាំងពីឆ្នាំ២០០៣នេះ បើឪពុកខ្ញុំគាត់ស្លាប់ឆ្នាំពីរពាន់អើ កាលនិងខ្ញុំនៅប្រហែលជាអាយុ២០ ម្តាយខ្ញុំស្លាប់មុន ដល់ចឹងទៅខ្ញុំនៅចិញ្ចឹមឪពុកខ្ញុំរហូតចឹងទៅណា។

ក៖ ចារហើយខ្ញុំចង់សួរអ្នកមីងទៀតថា ឪពុកម្តាយរបស់មីងគាត់មានឈ្មោះអីគេដែលមីង?

ខ៖ ចារគាត់មានឈ្មោះថាឪពុកខ្ញុំ ឈ្មោះ គុយ សួង ម្តាយខ្ញុំឈ្មោះ ហុង សឹម។

ក៖ ចារហើយចុះមីងចាំថាគាត់កើតនៅកន្លែងណាស្រុកណាដែល?

ខ៖ គាត់នៅភូមិឃុំខ្ញុំដែលនិង ភូមិព្រៃកឈើទៀលនិងម៉ង ស្រុកកំណើតគាត់គឺនៅនិងតែម្តង។

ក៖ ចារនៅខេត្តស្វាយរៀងទាំងអស់គ្នា?

ខ៖ ចារនៅខេត្តស្វាយរៀងទាំងអស់គ្នា។

កៈ ចារហើយខ្ញុំចង់សួរថា គាត់មានឆ្នាំខ្មែរអីគេដែលមីង?

ខៈ ឪពុកខ្ញុំគាត់ឆ្នាំ ឆ្លូវ ម្តាយខ្ញុំឆ្នាំខាល។ ប្អូនមួយឆ្នាំ បងមួយឆ្នាំ ពួកគាត់។

កៈ ចារហើយខ្ញុំចង់សួរមីងថាកាលពេលពួកគាត់ស្លាប់ កាលនិងមីងមានអាយុប៉ុន្មាន?

ខៈ ម្តាយខ្ញុំស្លាប់តាំងពីខ្ញុំនៅអាយុ ១៧ទៅ១៨ឆ្នាំ តែឪពុកខ្ញុំស្លាប់កាលនិងខ្ញុំមានអាយុ២៤ទៅ ២៥ឆ្នាំហើយ។

កៈ ចារពួកគាត់ស្លាប់ដោយសារជំងឺរក៏យ៉ាងមេចមីង?

ខៈ ចារពួកគាត់និងចាស់ៗអស់ហើយ ពួកគាត់មានអាយុច្រើនដែលហើយ ម្តាយខ្ញុំស្លាប់៦៧ឆ្នាំ ឪពុកខ្ញុំស្លាប់៧៤ឆ្នាំ។

កៈ ចារចឹងពេលពួកគាត់ស្លាប់អស់ហើយបានមីងរើមកនៅភ្នំពេញមែនមីង?

ខៈ ចារវាដូចជាចៃដន្យដែលណា ខ្ញុំអត់ពីគាត់យើងមានប្តីហើយ ក៏មករកស៊ីតាមប្តីមក តែ យើងមានប្តីហើយយើងអត់មានសំណាងទេអូនអើយ គាត់ជនជាតិវៀតណាមដល់ពេលចឹង ទៅគាត់មិងសួរគិតយើងពួកខ្មែរទេអូនអើយ យើងចិញ្ចឹមកូនតែម្នាក់ឯងរហូតចឹងទៅ ចឹងបាន ថាខ្ញុំវាអត់មានសំណាងអីទេ តែយើងទៅតូចចិត្តអីបើអានិងវាជាវាសនារបស់យើងចឹងទៅណា ដល់ចឹងទៅយើងវាអាណិតកូន ព្រោះយើងមិនបានអោយវារៀនសូត្រអីទេណា ខ្ញុំមកធ្វើការចឹ ងទៅកូនវាចេះតែមកតាមម្តាយ ខ្ញុំទៅធ្វើការអោយគេដល់រតនះគីរី មណ្ឌលគីរី ដើរស៊ីឈ្នួលគេ ដកដំឡូវ ដកអីចឹងទៅតាំងពីមុនៗមក មុនខ្ញុំពោះធំមីនោះទៀតនុះ និយាយពីរឿងដើរខ្ញុំដើរ សព្វអស់ហើយខ្ញុំ ដើរសព្វគ្រប់អស់ហើយយើងធ្វើការដោយកំម្លាង យើងអត់មានជំរិះអីយើង ស៊ីឈ្នួលគេតាមកំលាំងណា យើងប្រើកំម្លាំងធ្វើការ។ វាមិនមានអីច្រើនទេ គ្រាន់តែថាយើងវា មិនមានអីទេ យើងចេះតែប៉ងប្រាថ្នារថាអោយជីវិតអីរីកចំរើន តែយើងមិនដឹងថាធ្វើអីទេ មាន តែកំម្លាំងនិង យើងមានជំរិះចេះអីណា។

កៈ ចារហើយខ្ញុំចង់សួរអ្នកមីងទៀតថាពេលឪពុកអ្នកមីងគាត់នៅរស់ តើគាត់ប្រកបរមុខរបបអ្វី សំរាប់ចិញ្ចឹមជីវិតដែលមីង?

ខៈ ឪពុកខ្ញុំគាត់អ្នកធ្វើស្រែ ឡើងត្នោតអីចឹងទៅណា ព្រោះគាត់ជាអ្នកស្រែ។

កះ ចារហើយពួកគាត់គឺជាមនុស្សបែបណាដែលសំរាប់មីង?

ខះ ពួកគាត់ាមានអី ពួកគាត់ល្អ ពួកគាត់ផ្តល់ភាពកក់ក្តៅអោយយើងដែល គាត់មិនដែលទៅនិយាយអីធ្ងន់ៗទេ គ្រាន់តែថាគាត់មិនមានអីអោយយើងទេ ពួកគាត់អ្នកស្វាយរៀងមិនមានគេអាករដីធីអីច្រើនទេ។

កះ ចារហើយចុះម្តាយមីងគាត់ប្រកបមុខរបស់អីសំរាប់ចិញ្ចឹមជីវីតដែលមីង?

ខះ គាត់ជំនាន់គាត់និងមានអី ពួកគាត់មានតែធ្វើស្រែ ធ្វើអីនិង។

កះ ចារពួកគាត់ធ្វើស្រែទាំងប្តីទាំងប្រពន្ធ?

ខះ ចារធ្វើស្រែទាំងប្តី ទាំងប្រពន្ធ គាត់មិនដែលបានទៅស៊ីឈ្នួលអី បើគាត់ចាស់អស់ហើយមិនដូចយើងក្មេង គាត់ចាស់ៗចឹងគ្មានកំម្លាំងទេ យើងកើតមកឃើញគាត់ចាស់តែម្តង។

កះ ចារហើយចឹមីរកូនពៅគេ? ចុះម្តាយមីងគាត់គឺជាមនុស្សបែបណាដែលសំរាប់មីង?

ខះ ចារខ្ញុំកូនពៅគេ គាត់ស្រលាញ់កូនទាំងអស់គ្នា គាត់មិនដែលទៅខឹងស្អប់កូនអីទេ ម្តាយខ្ញុំគាត់ជាមនុសល្អណាស់ ដូចតែយើងជាម្តាយ យើងស្រលាញ់កូនយើងរាល់ថ្ងៃនិងចឹងណា ដូចគ្នារ។

កះ ចារហើយខ្ញុំចង់សួរមីងទៀតថា តើពួកគាត់ធ្លាប់និយាយអីប្រាប់ពីមីងពីជិវិតនិងពីប្រវត្តិគាត់អីប្រាប់មីងដែលទេ?

ខះ ចារពួកគាត់ធ្លាប់និយាយប្រាប់តាស់ គាត់ប្រាប់កូនថាពួកគាត់មិនដែលទៅរកស៊ីអីនៅឆ្ងាយពីស្រុកក្រៅអីទេ មិនដែលបានទៅស៊ីឈ្នួលអ្នកណាគេទេ គាត់និយាយប្រាប់កូនចឹងណា ហើយគាត់ចឹញ្ចឹមជ្រូក ចិញ្ចឹមមាន់អីខ្លះៗចឹងណា សំរាប់កូនទៅលេងបុណ្យភ្ជុំ ចូលឆ្នាំខ្មែរអីចឹងណា នៅខាងនិងគេមិនសូវចាយលុយទេ គេហូបតែបាយនិង គឺហូបតែបាយតែម្តងខាងស្វាយរៀង ហាហារ។

កះ ចារហើយសូមសួរអ្នកមីងទៀតថាជីដូនជីតាខាងឪពុកមានឈ្មោះអីគេដែរមីង?

ខ៖ ចារតាខ្ញូមានឈ្មោះថា តាប្រាក់ យាយឈ្មោះ យាយអ៊ុន។ ហើយម្ដាយខាងអើម្ដាយខ្ញុំមានឈ្មោះ យាយអួន តាគិត តែត្រកូនពួកគាត់មិនដឹងឈ្មោះអីទេខ្ញុំមិនសួរបានដឹងដែលចឹងណា ព្រោះម៉ែខ្ញុំគាត់មិនបានសួរណែនាំស្គាល់គាត់ទេ។

ក៖ ចារហើយចុះពេលមីងនៅពីតូចនិងធ្លាប់រស់នៅជាមួយយាយតាដែលឬទេ?

ខ៖ ខ្ញុំកើតមកនិងអត់ទេ អាឡូវមកដល់កូនខ្ញុំនិងក៏ចឹងដែល មិនដែលមានយាយមានតាផង ព្រោះគាត់ស្លាប់អស់ហើយ។

ក៖ ហើយខ្ញុំចង់សួរអ្នកមីងទៀតថា អើមីងធ្លាប់ដឹងថាជីដូនជីតាមីងកើតនៅស្រុកណាដែល?

ខ៖ ដ៏ដែល ពួកគាត់កើតនៅស្រុកដ៏ដែលនិង គឺស្វាយរៀង។

ក៖ ចឹងនៅស្វាយរៀងទាំងអស់គ្នា?

ខ៖ ចារនិងហើយប្ដីខ្ញុំគាត់ក៏ជាអ្នកភូមិតែមួយជាមួយគ្នាដែល។

ក៖ ហើយជីដូនជីតាមីងពួកគាត់ស្លាប់នៅជំនាន់ណាដែលមីង?

ខ៖ បងហារ ម្ដាយយើងស្លាប់នៅជំនាន់ណាចែ?

គ៖ គាត់អាយុអើ។

ខ៖ អត់ទេជីតាយើងណា?

គ៖ អរពួកគាត់ស្លាប់យូរហើយ តាំងពីកំណើតខ្ញុំនុះ ខ្ញុំអាឡូវ ខ្ញុំ៥៣ក្នុងឆ្នាំនិងហើយ ព្រោះបន្ទាប់ពីខ្ញុំបានប្អូនខ្ញុំនេះវាកើត មើលអាឡូវវាឆ្នាំ វាចូល៣៩ ទៅ៤០ឆ្នាំ ចឹងគាត់ស្លាប់ជាង៤០ឆ្នាំហើយ។

ក៖ ចារគាត់ស្លាប់នៅជំនាន់ប៉ុលពតឬក៏មុនជំនាន់ប៉ុលពតនិងទៀត?

គ៖ អរមុនៗ មុនជំនាន់ប៉ុលពតទៀតប្រហែលជា២០ឆ្នាំនុះ។ តាខ្ញុំនិងយាយខ្ញុំទាំងសងខាង ខាងឪពុកម្ដាយខ្ញុំពួកគាត់ស្លាប់ទាំងអស់និង ខ្ញុំកើតនៅជំនាន់ប៉ុលពត ឃើញតែយាយខ្ញុំទេ យាយខ្ញុំនិងមួយកំណើតខ្ញុំនិង ដល់ខ្ញុំមានអាយុ១២ឆ្នាំ គាត់ស្លាប់មកដល់អាឡូវចូលជាង៤០ឆ្នាំ ទៅ៥០ឆ្នាំបាត់ អាឡូវនិងខ្ញុំមានអាយុ៥២ឆ្នាំហើយ។

កៈ ចារអរគុណមីង។ ហើយខ្ញុំចង់សួរមីងទៀតថាបងប្អូនមីងដែលបានរៀបការហើយនិងតើគាត់ប្តូទីលំនៅទៅរស់នៅកន្លែងណាដែល?

ខៈ ពួកគាត់នៅដូចថាភូមិជិតៗគ្នាចឹងណា ភូមិគេនិងមិនមែននៅជាមួយគ្នាទេគ្រាន់តែថាភូមិវាជិតៗគ្នាចឹងណា។

កៈ ចារចឹងពួកគាត់រៀបការរួចនៅជិតៗគ្នា ក៏បំបែកគ្នាចឹងទៅ?

ខៈ ចារអោយនៅបែកគ្នាចឹង ព្រោះឪពុកម្តាយខ្ញុំគាត់មិនសូវចង់អោយកូនចៅអីនៅជាមួយគ្នាអីទេ ចង់អោយបែកទៅអោយចេះប្រឹងរកស៊ីរៀងៗខ្លួន ដើម្បីអោយដឹងមានដឹងក្ររៀងខ្លួនចឹងណា គាត់មានដីតិចតួចចែកកូនអោយធ្វើផ្ទះធ្វើអីនៅចឹងទៅ ដើមឈើ ដើមព្រៃអីគាត់មានចឹងណាគាត់អោយកូនចៅយកទៅធ្វើទៅ។

កៈ ចារចឹងអើអ្នកមីងមានសាច់ញាតិបងប្អូនអីដែលរស់នៅក្រៅប្រទេសទេមីង?

ខៈ ខ្ញុំមិនដែលមានទេ។

កៈ ចារអត់សោះតែម្តង ហើយខ្ញុំចង់សួរអ្នកមីងទៀតថាតើអ្នកមីងចង់ចាំអំពីកាលនៅជំនាន់ប៉ុលពតណា តើមីងធ្លាប់ឆ្លងកាត់សម័យនិងទេមីង?

ខៈ អើបើនិយាយទៅខ្ញុំដូចជាមានវាសនាណាស់កូន កុំអីម៉ែខ្ញុំក៏មិនដាក់ឈ្មោះខ្ញុំថាវាសនាដែល។ ថ្ងៃដែលគេយកទៅ គេយកឪពុកម្តាយខ្ញុំទៅសំលាប់ ថ្ងៃនិងបងខ្ញុំអីទៅអស់រលីង ដល់ចឹងក៏កើតខ្ញុំនៅក្នុងថ្ងៃនិង ថ្ងៃដែលគេយកទៅសំលាប់និងថ្ងៃនិងក៏គេរំដោះតែម្តង ដល់ចឹងទៅក៏ម្តាយខ្ញុំនិងក៏ដាក់ខ្ញុំឈ្មោះថាវាសនា ដល់ចឹងទៅវាពិបាក។

កៈ ចារហើយចឹងអ្នកមីងកើតនៅសម័យប៉ុលពត?

ខៈ ខ្ញុំកើតចំថ្ងៃនិងជាថ្ងៃរំដោះ ហើយក៏ជាថ្ងៃដែលគេយកទៅសំលាប់ទាំងពូជតែម្តង តែខ្ញុំកើតនៅថ្ងៃនិងចឹងទៅក៏ម៉ែខ្ញុំដាក់ឈ្មោះខ្ញុំថា វាសនា និងតែម្តង។ ប៉ុន្តែអុំៗខ្ញុំអីទៅស្លាប់អស់រលីងតែនៅម្តាយខ្ញុំគាត់ដើរៗទៅក៏កើតខ្ញុំ ដល់ចឹងទៅគាត់អត់បានទៅមុខចឹងទៅក៏ត្រូវរស់។

កៈ ចារហើយឪពុកម្តាយមីងស្លាប់នៅសម័យប៉ុលពត ឬក៏ក្រោយប៉ុលពត?

ខៈ ពួកគាត់ស្លាប់នៅជំនាន់ក្រោយប៉ុលពត។

ក៖ ហើយសុំសួរអ្នកមីងថាស្វាមីរបស់មីងតើគាត់មានឈ្មោះអីដែល?

ខ៖ គាត់មានឈ្មោះថា ជាតាំម។

ក៖ ឈ្មោះជាតាំម ហើយអ្នកមីងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែលមីង?

ខ៖ អើខ្ញុំនិងគាត់និងស្រលាញ់គ្នា ដល់ស្រលាញ់គ្នាទៅក៏គេយកយើងនិងទៅរៀបខាងប្រុស មិនបាននៅរៀបខាងស្រីយើងទេ នុះទៅរៀបការនៅវៀតណាមនុះ គេខាងស្អីគេទេមីងមិនដឹងទេ នៅខាងយើងនេះថារករៀប មានបានរៀបអីខ្ញុំនេះពោះធំក៏ចុះអតាស៊ីវិលទៅនៅខាងយើងនេះណា ប៉ុនន្តែឪពុកម្តាយខ្ញុំនិងក៏ស្រលាញ់គាត់ដែលមិនងត់ទេ បើឪពុកខ្ញុំទាន់គាត់ បើម្តាយខ្ញុំនេះអត់ទាន់គាត់ទេព្រោះម្តាយខ្ញុំគាត់ស្លាប់នៅមុននិង ចឹងឪពុកខ្ញុំគាត់ទាន់។

ក៖ ចារចឹងឪពុកអ្នកមីងស្រលាញ់គាត់ដែល?

ខ៖ ចារស្រលាញ់។

ក៖ ចារពេលរៀបការរួចនាំគ្នាទៅនៅខាងមីងឬក៏ទៅនៅខាងគេនុះមីង?

ខ៖ ចារគាត់មកនៅខាងខ្ញុំនេះ ព្រោះខ្ញុំនៅតែពីរនាក់ឪពុកខ្ញុំដល់ចឹងទៅក៏ខ្ញុំមកនៅនេះ។

ក៖ ហើយខ្ញុំសុំសួរមីងទៀតថា ពេលដែលអ្នកមីងជួបគាត់ដំបូងនៅកន្លែងណា ហើយហេតុអីបានជាអ្នកមីងស្រលាញ់គាត់ហើយយល់ព្រមរៀបការជាមួយគាត់?

ខ៖ អើស្រលាញ់គ្នាតាំងពីយូឆ្នាំហើយ តែមិនសមថាគាត់ចឹងសោះ តែអាឡូវក៏វានៅតែមិនទាន់ហួសពេល ទោះគាត់អាក្រក់ល្អប៉ុនណាក៏នៅតែជាប្តី និងជាឪពុករបស់កូន។

ក៖ ចារចង់សួរមីងថាពេលមីងជួបគាត់ដំបូងតើគាត់ល្អបែបណាបានធ្វើអោយមីងសំរេចចិត្តរៀបការជាមួយគាត់ណា?

ខ៖ គាត់មើលទៅដូចជាស្លូតដែលមើលទៅនុះ បើនិយាយទៅគឺស្លូតតែម្តង។

ក៖ ចារហើយយ៉ាងមេចទៀតមីង។

ខ៖ មើលទៅទំនងជាអ្នកដែលអោយយើងផ្ញើអនាគតបានណា តែមានអីដល់ពេលមានកូនមានចៅទៅខ្ញុំមិននឹកស្មានថាគាត់បែកគំនិតទៅជាចឹងទៅ។

កៈ ចារចឹងមីងអាចនិយាយពីប្រវិត្តដែលអ្នកមីងជូរចត់ពិបាកបានទេ?

ខៈ ចារជីវិតខ្ញុំនិយាយថាពិបាក ដូចថាប្ដីខ្ញុំជាប្រវិត្តជូរចត់របស់ខ្ញុំ ខ្ញុំវាពិបាកមិនហ៊ាននិយាយប្រាប់អ្នកណាទេ តែខ្ញុំសុខចិត្តពិបាកខ្លួនឯងតែម្ដងណា មិនអោយអ្នកដ៏ទៃណាមកលុកដៃទេ ខ្ញុំមិនចង់គិត។

កៈ ចារតែអ្នកមីងត្រូវតែតស៊ូដើម្បីចិញ្ចឹមកូន។

ខៈ ចាររាល់ថ្ងៃខ្ញុំខំប្រឹងដើម្បីចិញ្ចឹមកូន ថាកូនវាមិនបានរៀនក៏អត់ទៅចុះ តែអោយតែកូនបានដំរិះអោយតែវាធំវាអាចរកស៊ីបានចិញ្ចឹមខ្លួនឯង ព្រោះខ្ញុំនេះមិនមានអីចែកគាត់ទេ មានតែប្រឹងចិញ្ចឹមគាត់អោយធំហើយគាត់រកស៊ីខ្លួនឯងអីចឹងទៅ អានិងខ្ញុំនិយាយប្រាប់ប្អូនឯងត្រង់។

កៈ ចារមីង។

ខៈ ខ្ញុំវាមិនដឹងទៅណា ចេះតែរកចិញ្ចឹមកូនដឹងទៅណាកើត បើរត់ទៅក្រែងលោះក្រវារត់ទៅតាមដល់និងទៀត ហាហារ គេថាចឹង និយាយពីថាខំគេចក្រនុះគេច វានៅតែទៅតាមរកឯងទៀត ហាហារដល់ចឹងទៅខ្ញុំមិនចេះយំមិនចេះថាពិបាកអីទេ អោយធ្វើមេចបើវាចឹងទៅហើយ ហាហារដើម្បីចិញ្ចឹកូនខ្ញុំចេះតែខំប្រឹងទៅ តែអរគុណចំពោះក្មួយៗដែលមានពេលវេលាមកសំភាស៍មីងចឹងទៅ មីងសំបាយចិត្ត គិតថាសប្បាយ ហាហារ។

ខៈ ចារហើយខ្ញុំសុំសួរអ្នកមីងទៀតថាអ្នកមីងបានរៀនដល់ថ្នាក់ទីប៉ុន្មាន?

ខៈ អើរៀនបានត្រឹមថ្នាក់ទីមួយ រវល់ដើររើសអាច់គោរយកទៅដុតភ្លើងស្គរ យកទៅដុតភ្លើងស្គរ ប៉ុនន្តែនៅថ្នាក់ទីមួយអោយមើលអក្សរបានដែល តែអោយសរសេរអត់ចេះទេ។

កៈ ចឹងមិងអត់ចេះអានអត់ចេះសរសេរអីទេ?

ខៈ អានខ្ញុំចេះ ប៉ុនន្តែសរសេរខ្ញុំអត់ចេះទេ អត់ទេ។

កៈ តែមីងអាចអានបាន?

ខៈ ចារស្អីក៏អានដែល ហើយអាសូរថារៀនបានច្រើនទៅមិនថាទេ ខ្ញុំរៀនបានតែប្រាំរខែអាចអានបានខ្លះ ចឹងគិតថាចេះ។

ក៖ ចាររួចចុះអ្នកមីងចេះនិយាយភាសារអ្វីផ្សេងក្រៅពីភាសារខ្មែរដែលទេ?

ខ៖ ខ្ញុំចេះនិយាយវៀតណាមតិចតួច ព្រោះប្តីមីងវៀតណាម ហាហារ។

ក៖ ចឹងប្តីមីងបង្រៀនមីងមាន?

ខ៖ អត់ទេ ខ្ញុំប្រឹងស្តាប់គេនិយាយ គាត់មិនដែលបានបង្រៀនខ្ញុំទេ ចេះតែរៀនស្តាប់គេនិយាយ ពីហូបបាយ ហូបទឹកក្នុងគ្រួសារ និងទិញនេះទិញនុះអីចឹងចយើងអាចនិយាយបាន។

ក៖ ចារហើយមីងធ្លាប់រស់នៅជាមួយក្រុមគ្រួសារកាត់ទេ?

ខ៖ ក្រុមគ្រួសាគាត់ពួកវៀតណាមនិងខ្ញុំនៅតែជាមួយនិងគេនិង ប្អូនថ្លៃអីមកនៅជាមួយរហូតនិង ដល់តែបងវាទៅ ក៏វាទៅជាមួយនិងគេនិងទៅពីរនាក់បងប្អូនគេនិងក៏ទៅបាត់ទៅ។

ក៖ ចារដល់ពេលគេមានប្រពន្ធមួយទៀត គាត់ទៅនៅស្រុកវៀតណាមឬក៏នៅណាដែលមីង?

ខ៖ នៅនិងស្រុកខ្មែរយើងនិង ប្រពន្ធខ្មែរដែលវានៅជិតនេះដែល តែខ្ញុំមិនទៅទេ ទៅធ្វើអី។

ក៖ ចារហើយគាត់មានជួយផ្តល់លុយ ផ្តល់កាក់សំរាប់ចិញ្ចឹមកូនដែលទេមីង?

ខ៖ អត់ទេអូន អត់សោះម៉ង។ ខ្ញុំឆ្លងទន្លេ(កើតកូន)ប៉ុនណាណីប្រាប់ទៅប្អូនគាត់ គាត់បិទលេខទូរស័ព្ទគាត់ ប្អូនគាត់ ខ្ញុំមិនចង់បានអីពីគាត់ទេ ខ្ញុំមានអង្គារជួយខ្ញុំ ប៉ុនន្តែអង្គារនិងនៅក្នុងមួយភូមិនិងក្រជាងគេគឺខ្ញុំនិងតែម្តង ខ្ញុំពឹងគេ ទៅដល់ខ្ញុំធ្វើការនៅឪរ៉ាលនិង ខ្ញុំគ្រុនចាញ់ពោះធំប្រាំរបីខែនិងក្រពេក ក៏ប្រធានភូមិគេអោយខ្ញុំមួយសន្លឹក(លុយ១០០ដុល្លា)ហើយទៅដល់អង្គារនិងទៅហើយខ្ញុំមានប័ណ្ណបសសពីរោងចក្រនិងទៅ ដល់ពេលទៅដល់នេះគេមានអង្គារគេក្មេងៗដូចអូនឯងចឹងណា ទៅដល់គេទទួលយើង ហើយខ្ញុំនិយាយប្រាប់គេថាខ្ញុំគ្រុនចាញ់ ហើយគេមើលខ្ញុំនិងកើតកូននៅនិងគ្រុនចាញ់មើលយើងជាហើយគេអោយលុយប្រាំម៉ឺនមកទៀត រួចអង្គារនិងគេជូនយើងមកដល់ផ្ទះទៀត មិនមែនផ្ទះខ្លួនឯងទេ ខ្ញុំនៅផ្ទះគេទៀតនៅក្នុងរោងម៉ាស៊ីនគេ។

ក៖ ចារហើយចឹងមីងពូនៅពេលដែលគាត់ទៅនិង គាត់រៀបការជាមួយស្រីផ្សេងឬក៏យ៉ាងមេចដែលមីង?

ខ៖ នៅជាមួយគ្នាអត់មានរៀបការទេ។

កៈ ចឹងគាត់ទៅរស់នៅជាមួយស្រីផ្សេង?

ខៈ ចារគាត់មិនបានរៀបចំការទេ។

កៈ ហើយខ្ញុំចង់សួរមីងទៀតថាមីងមានមិត្តភ័ក្តដែលធំឡើងស្និទស្នាលជាមួយគ្នាដែលឬទេមីង?

ខៈ មានតែពួកគាត់នៅស្រុកៗនុះ នៅក្នុងភូមិជាមួយគ្នានៅនិង នៅក្រមុំៗជាមួយគ្នាធ្លាប់ដើររាំតាមរោងបុណ្យរៀងការអីចឹង។

កៈ ហើយពួកគាត់មានឈ្មោះអីគេដែលមីង?

ខៈ ឈ្មោះបងថៃ ពួកគាត់និងសុទ្ធតែបងយើងមួយឆ្នាំណា បងរ៉ន បងធីម ពីនាក់និងកូនភ្លោះបងយ៉ន បងរ៉ុនអីចឹងទៅ មិត្តភ័ក្តខ្ញុំនៅពីតូចច្រើនណាស់ខ្វះអី ប៉ុន្តែគេសុទ្ធតែមានសំណាំងប្តីគេមាន ប្តីគេនៅស្រុក យើងអត់ មានប្តីដែលប៉ុន្តែយើងចាក់ចេញមករកស៊ីនៅនេះចឹងណា គេមានប្តីគេនៅរកស៊ីក្នុងស្រុក ក្នុងភូមិ ចំនែកខ្ញុំវិញប្តីប្រពន្ធដើររកស៊ីឆ្ងាយៗ ទៅតាមប្តីដល់បោយប៉ែត បាត់ដំបង ពោត៍សាត់ សៀមរាប បើកំពង់ធំវិញ ខ្ញុំទៅនៅនិងដប់ឆ្នាំ កំពង់សោអីនិងខ្ញុំទៅនៅមិនមែនទៅនៅធ្វើអីទេ គឺទៅធ្វើសំណង់ ខ្ញុំទៅតាមប្តីធ្វើសំណង់ តែមិនសល់អីទេ នៅសល់តែកូន អានិងសល់ហើយនិងកំណប់របស់ខ្ញុំ ហាហារ ខ្ញុំនិយាយថាចឹង។

កៈ ហាហារចារមិនអីទេមីង។

ខៈ និងជាកំណប់របស់ខ្ញុំ ប៉ុនន្តែលុយកាក់យើងអាចរកបានទេ ក្រែងលោមានសំណាងពេលគាត់ធំៗទៅពួកកូនៗខ្ញុំណា អាឡូវយើងកំពុងតែពិបាក ពេលពួកគាត់ធំៗទៅក្រែងលោកគាត់ជួយរកការងារ ប៉ុនន្តែមិនដឹងធ្វើការអោរអីទេ ព្រោះពួកគាត់សុទ្ធតែមិនបានរៀនសូត្រចឹង ធម្មតាធ្វើការនិងកំម្លាំងស៊ីឈ្នួលគេអីអាចបានចឹងដែល។

កៈ ចាំមើលពួកគាត់ធំៗតិចទៀតមើលមីង។

ខៈ ចារនិងហើយ គេចង់រៀនតាស អាឡូវលើគេសាលាគេ។

កៈ ចុះមីងគិតថាសាលារដ្ឋអី គេចុះឈ្មោះចូលរៀនអត់អស់លុយអីមីងអាចយកគាត់ទៅ?

ខ៖ តែខ្ញុំលឺគេនិយាយថា ពួកគេរកអាត្រកូលដ្ឋាន(សំបុត្រកំណើត)អីនិងយកស្អីៗចឹងណា ខ្ញុំវាមិនសូវស្គាល់គេអីចឹង ហើយណាមួយអារម្មណ៍កំពង់ធ្វើការពេលកូនមិនទាន់មកដល់ផ្ទះយើងបែកអារម្មណ៍ណាធ្វើការមិនកើត បើសិនជាអត់មួយថ្ងៃពួកយើងក៏អត់ដែល អត់ការងារធ្វើមួយថ្ងៃក៏អត់ដែល ហើយចឹងសុខចិត្តអោយគាត់នៅមើលគ្នាគាត់តូចៗនិងទៅ យើងរកតាមកំម្លាំងយើង រកតែបាយនិងជួលតែផ្ទះអោយគាត់សំងួមនៅទៅ មើលទៅពួកគាត់ក៏ចង់រៀនសូត្រដែលប៉ុន្តែគាត់ មិនទាន់មានលទ្ធភាព។

ក៖ ចារហើយអើខ្ញុំចង់សួរអ្នកមីងទៀតថា។

ខ៖ ចារសួរមកអ្នកគ្រូ សួរមិនបាច់ខ្លាចចិត្តទេ។

ក៖ ចារតើអ្នកមីងអាចចង់ចាំអំពីសាច់រឿងអីខ្លះដែលអ្នកមីងធ្លាប់លេងជាមួយមិត្តភ័ក្តតាំងពីនៅក្មេងៗណា?

ខ៖ អើខ្ញុំមិនដែលបានលេងអីដែលគួរអោយចាប់អារម្មណ៍ទេ ខ្ញុំដើរស៊ីតែឈ្នួលគេរហូត ធ្វើនៅភ្នំពេញ នៅខេត្តអីចឹងទៅណា បើថានៅពីតូចប៉ុនៗកូននេះខ្ញុំនៅជាមួយនិងគ្រួសារ មកដល់វ័យជំទង់ហើយខ្ញុំក៏មកនៅខេត្តគេនេះធ្វើការអោយគេ យកលុយទៅអោយឪពុកម្តាយចឹងទៅណាគាត់ខ្វះខាតដែលចាស់ចឹង យើងនេះក៏មិនចេះអី ថារៀនមិនបានរៀនផងរៀនបានតែប្រាំរខែ។

ក៖ ចារនេះជាជីវិតរបស់មីង។

ខ៖ ចារអូន សួរមីងទៀតមក។

ក៖ ចារខ្ញុំចង់សួរអ្នកមីងទៀតថា អើអ្នកមីងធ្លាប់ធ្វើការនៅវាលស្រែទេ?

ខ៖ អើស៊ីឈ្នួលដកស្ទង់អោយគេនិងឡើងឆ្អែតចិត្តហើយ ដកស្រូវទៅមកកង់ធ្លាយយកអង្កទៅដូរគេអោយគេធ្វើកង់អោយរួចបានកង់ដឹកស្រូវ ដឹកអង្ករមកជិះពីផ្ទះទៅធ្វើកង់ មានប្តីសំណង់ចេះធ្វើសំណង់តាមប្តី ទៅធ្វើការរោងចក្រចេះធ្វើម៉ាស៊ីនទៀត ឃីចេះច្រើនយើងទល់ចេះធ្វើទៅវាធ្វើអោយយើងចេះគួរសម ប៉ុន្តែមិនធ្វើអីអោយហួសពីកំម្លាំងមានទេ មិនលួចគេ ទេមិនចេះហើយក៏មិនលួច។

ក៖ ចារហើយកាលមីងធ្វើស្រូវស៊ីឈ្នួលអោយគេនិងគេអោយកំរៃជាលុយ ឬក៏ជាអ្វីដែលមីង?

ខ៖ យើងចង់បានលុយគេអោយលុយ យើងចង់បានអង្ករគេអោយជាអង្ករមក យកអង្ករមកហូប។

ក៖ ហើយបន្ទាប់ពីនិងមីងធ្លាប់លក់ដូរ ឬក៏រកស៊ីអីផ្សេងទៀតទេ?

ខ៖ ខ្ញុំធ្លាប់ដើរលក់ស្ករ ជិះកង់ដើរលក់ស្ករ។

ក៖ ចារហើយស្ករនិងមីងទិញគេឬក៏ធ្វើខ្លួនឯងមីង?

ខ៖ អើមិនបានធ្វើខ្លួនឯងទេ ទិញពីគេចំនេញមួយថ្ងៃបាន ៣០០០រៀល ទៅ២០០០រៀល តែកាលនិងលុយថ្លៃ ថ្លៃច្រើនមែនទែនណា ខ្ញុំអរណាមកដល់ផ្ទះវិញ ទិញប្រហុកមួយគីឡូតែមួយពាន់រៀលក៏មានដែលកាលនិងនុះ ចំនេញមួយថ្ងៃៗ ឆ្លៀតទិញប្រហុក ទិញអំបិលទុក ទីញនេះទិញនុះ គេមានដូមាន់យើងដូរមាន់ទៀតយកមកផ្ទះអោយបានសព្វគ្រប់ទៅណា។

ក៖ ហើយខ្ញុំចង់សួរអ្នកមីងទៀតថា អើតាំងពីតូចរហូតមកដល់អាឡូវនិងតើអ្នកមីងមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងជីវិតរបស់មីង?

ខ៖ ពេលកាលយើងនៅជាមួយបងប្អូនឪពុកម្តាយបងប្អូនជុំគ្នាដូចជា កាលនិងយើងអត់មានអារម្មណ៍ថាចេះស្គាល់ពីរអារម្មណ៍អ្នកណាអ្នកណាចឹងណា ដល់ពេលយើងម្នាក់ឯងខ្លួនទីពឹងខ្លួនវាពិបាក ហើយពិបាកខ្លាំងបំផុតអានិងគេហៅថាខ្លាំងណា មិនខ្សោយទេ ថាខ្លឹងម៉ង។

ក៖ ចារហើយកាលពីក្មេងមកតើអ្នកមីងឃើញការផ្លាស់ប្តូរអីគេខ្លះនៅក្នុងជីវិតរបស់មីង?

ខ៖ ផ្លាស់ប្តូការនៅលាវអត់មានកូនវាពិបាក ដល់ពេលមានប្តីមានកូនវាពិបាកថែមមួយទៀតហើយ។

ក៖ ហាហារ នៅលាវពិបាកហើយ ដល់មានប្តីមានកូនពិបាកទៀត ហាហារ។

ខ៖ ពិបាកទៀតហើយ ហាហារ ប៉ុន្តែមិនពិបាកអីខូចចិត្តសំលាប់ខ្លួនទេ ទៅលេបថ្នាំអី អត់ទេមិនភ្លើទេ ខ្ញុំវាអាណិតពួកគាត់អត់មានឪពុកហៅហើយ បើយើងធ្វើចឹងទៀតវាពិបាក ដល់ចឹងទៅខ្ញុំក៏ប្រឈរខ្លួនថាមានហូបឬក៏អត់ហូបកុំអោយកូនគាត់ពិបាកចិត្តទៀត ព្រោះគ្នាវាឯកកោរហើយ ដល់ចឹងទៅយើងវាខ្វិលពិបាកចិត្ត ហើយយើងក៏គិតខ្លីៗចេះតែថាជូនពរប្តីអោយមានសុភមង្គលល្អទៅ ទៅនៅជាមួយពួកយើងគ្រែងលោគាត់រកស៊ីចិញ្ចឹមពួកយើងមិនកើតអោយ

គាត់ទៅរកស៊ីចិញ្ចឹមពួកនោះចុះ ហើយគាត់ចាស់អីខ្ញុំក៏មិនដែលទៅជេខឹងអីគាត់ដែលមិនដែលទៅជេអី បើថាចាស់ទៅគាត់ត្រលប់មកវិញអី ខ្ញុំក៏អោយកូនចិញ្ចឹមគាត់ទៅ ពេលកូនគេធំៗអីព្រោះខ្ញុំចិត្តវាមិនដាច់ទេ ដូចថាបើគាត់ដឹងថាកូនគាត់ពិបាកចឹងមិនមែនគាត់ទៅចោលពួកយើងទេ អាឡូវគាត់នៅមានកម្លាំងគាត់នៅរកស៊ីចិញ្ចឹមគេនៅនោះណា តែបើគាត់ចាស់ទៅគេនុះអត់កូនដែលនិង ចាស់ទៅគេមករកកូនខ្ញុំ ពិបាកចិត្តណាស់ រាល់ថ្ងៃ ខ្ញុំមិនគិតថា មិនគិតអី តែក៏មិនប្តាច់គាត់ គាត់នៅតែតេហៅកូនគាត់ទៅហូប ប៉ុន្តែខ្ញុំថាមិនអោយកូនទៅទេ តែយើងក៏មិនប្រាប់កូនអាក្រក់ថា ឪពុកហ្អែងមិនចិញ្ចឹមហ្អែងទេ ហ្អែងកុំរាប់អានគាត់អី ខ្ញុំមានតែថាកូនឯងទៅៗតែកុំទៅនៅនិងគេ បើទៅលេងក៏ទៅៗ កុំទៅនៅនិងគេខ្ញុំនិយាយប្រាប់កូនតែប៉ុននិងបើគេចង់នៅនិងយើងមនបាច់ចាំហៅនឹកទេ ខ្ញុំគ្រាន់តែនិយាយចឹងណា និយាយចឹងពាក្យល្អឬក៏អាក្រក់ខ្ញុំគ្រាន់តែប្រាប់កូនប៉ុនិង ខ្ញុំសួរប្អូនៗចេះដឹងរៀនសូត្រ។

កៈ ចាវខ្ញុំគិតថាមីងធ្វើចឹងវាត្រឹមត្រូវព្រោះនេះជាក្តីស្រលាញ់របស់មីង ជាអំពើល្អរបស់មីង ចឹងទៅអំពើល្អនិង វានិងជួយយើងនៅថ្ងៃណាមួយ វានិងជួយយើងទៅដល់អោយយើងនូវអ្វីៗដែលល្អមកវិញ។

ខៈ អរគុណ សាធុក។

កៈ ចាវហើយខ្ញុំចង់សួមីងទៀតថា មិងមានម្ហូបអីដែលមីងចូលចិត្តហូប?

ខៈ អើខ្ញុំចូលចិត្តជាងគេរាស់ថ្ងៃ ប៉ុនន្តែធ្លាប់ហូបតែផ្អក់ និងប្រហុក។

កៈ ផ្អក់ ប្រហុកឆ្ងាញ់។

ខៈ សាច់គោសាច់អី យើងមិនទាន់មានលទ្ធភាព មិនទាន់ហ៊ានគិត មិនទាន់មានលុយដល់និង។

កៈ តែមីងចូលចិត្តអី រាល់ថ្ងៃ?

ខៈ ចូលចិត្តជាងគេខ្ញុំស្លរតែសំលរកកូរអីនិង ម្ហូបបែបស្រុកស្រែៗនិង និយាយអោយចំរាល់ថ្ងៃនិងយើងមានអី មានលុយអីទៅទិញអី ១០០០០រៀល ទិញម្ហូបហូបពិរពេលហើយរាល់ថ្ងៃនេះសំរាប់ជិវិត។

កៈ ចាវហើយសុំសួរមីងទៀតថាមីងធ្លាប់លេងល្បែងកំសាន្តអីគេខ្លះតាំងតែពេលក្មេងមក?

ខ៖ ខ្ញុំមិនសូវចេះអីទេអាឡូវចេះច្រើងការ៉ាអូយេណា ពីក្មេងអត់ចពទេអាឡូវចេះតែរាំអាឡូវ ចេះច្រៀងទៀតណា។

ក៖ ចារហើយមីងចេះលេងបោះអង្គុញ លេងអីទេ?

ខ៖ អរខ្ញុំលេងមិនអោយចេះគេទេ នេះអាញ៉ាអស់ហើយសាច់ លេងស្អីគេទេនុះជាមួយយាយ បងខ្ញុំ អាស្អីខ្លែងចាប់មាន់អស់រលីងហើយជើងដៃរ នុះយាយអង្គុយនៅក្រោមដើមចេកនុះ គាត់ មេក្រុមណា ហាហារ។

ក៖ ហាហារចូលចិត្តលេង ហាហារ។

ខ៖ អោយតែចូលឆ្នាំ គាត់ទិញដប់ស្រាអោយផឹងរហូតនុះ។

ឃ៖ តោះអ្នកណាចង់ទៅលេងណា តោះទៅលេងផ្ទះខ្ញុំបានសប្បាយ។

ខ៖ អាញ៉ាជើងរបួរអស់ហើយទៅលេងតែក្បែព្រៃបន្លារទេនុះ យាយនុះ ហាហារ រុញតែគ្នាងងក៏ មិនសល់ផងនិងយាយនិង។

ឃ៖ ហាហារ ខ្ញុំថាពេលលេង តោងគ្នាអោយជាប់ណា ខ្ញុំថាកុំប្រលែង ស្រាប់តែប្រលែងទៅនាំ គ្នាចូលព្រៃអស់រលីង មាននៅអីអត់ ហាហារ នៅពីក្មេងនិងសប្បាយមែន ចូលព្រៃអស់រលីង។

ក៖ ចារហើយខ្ញុំចង់សួរអ្នកមីងថា អ្នកមីងចេះច្រៀងទេ។

ខ៖ ចេះ ចេះច្រៀង។

ក៖ ហើយចុះអ្នកមីងចេះច្រៀងយូរនៅ?

ខើ អើចេះតាំងពីប្តីមានស្រីមក ចេះច្រៀង ហាហារ។

ឃ៖ អើច្រៀងមួយបទមើល ហាហារ។

ក៖ មីងចេះប្រៀងបទអី?

ខ៖ អើអាឡូវនិងចេះ ខ្ញុំអ្នកនៅស្វាយរៀងទៅច្រៀងបទអីក្រៅពីស្វាយរៀង ច្រៀងបទបុប្ផា ស្វាយរៀង ព្រោះ ហាហារ។

យ៖ ហើយចឹងច្រៀងតិចមើល។

ខ៖ ច្រៀងអីបើមិនទាន់ផឹកផង។

យ៖ អើសាក់តែស្រាចូលមើលបើមីនច្រៀងចេញអាឡូវ ហាហារ។

ក៖ ហាហារ ចារអ្នកមីងមិនអីទេចាំលើកក្រោយ ហាហារ ចាំខ្ញុំមកម្តងទៀត។

ខ៖ មកៗខ្ញុំនៅតែនិង។ ល្ងាចៗអីមក ល្ងាចមិញខ្ញុំផឹកស្រាឡើងសន្លប់នុះ។

ក៖ ហើយមេចបានទៅជាចឹងមីង?

ខ៖ សន្លប់កាលនិងគេហៅទៅច្រៀងទៅផឹកកុំអោយស្ងាត់រោង។

យ៖ អើវាច្រៀងបទ បងបំភ្លេចអូនចោលចុះ ហាហារ។

ខ៖ ហាហារ បងថ្ងៃខ្ញុំថាបើមានពីរនាក់លាក់ទុកមួយ យាយនេះហាហារ ចេះច្រៀងណាស់។

ក៖ ហាហារ ចំណែកអុំវិញចេះច្រៀងបទលួចស្រលាញ់គេតែម្នាក់ឯង ហាហារ។

ខ៖ ហាហារ សប្បាយណាស់ និយាយលេងនាំអោយក្មួយៗប្អូនៗសប្បាយចឹងណា។

ក៖ ចារមីងថ្ងៃសៅរ៍ខ្ញុំសុំមកម្តងទៀត មកជួបមីង ថ្ងៃសៅរ៍ពេលល្ងាចខ្ញុំមកជួបមីង។

យ៖ ថ្ងៃសៅរ៍ណាក្មួយ។

ក៖ សៅរ៍ក្រោយពេលល្ងាច។

យ៖ អូយេ ម៉ោងប៉ុន្មានក្មួយ?

ក៖ ម៉ោងប៉ុនន្មានមីង ប្រហែលម៉ោងបួន ម៉ោងប្រាំណា។

ខ៖ តែម៉ោងបួន ម៉ោងប្រាំនិងគាត់ចេញពីលក់វិញហើយ។

ក៖ មីងលក់ម៉ោងបួនប្រាំ ចឹងដោយខ្ញុំមកម៉ោងប៉ុន្មានមីង?

យ៖ អូនមកម៉ោងប៉ុន្មានក៏បានដែល ដប់មួយ ដប់ពីរអី។

កៈ ចារបានៗមីង។

ខៈ ផ្ទះខាងក្នុងទៅរកបេះស្វាយហូប នុះទុកស្វាយចោល។

កៈ ចារហើយខ្ញុំសុំសួមីងទៀតថាមីងធ្លាប់ស្តាប់បទស៊ុន ស៊ីសាមុទ ប៉ែនរ៉នអីដែលទេ?

ខៈ បទចាស់ៗចឹង ចូលចិត្តណាស់ ជិះក្របីក៏ច្រៀងដែលព្រោះចូលចិត្តណាស់ បើបទសម័យអាឡូវរឹតតែសប្បាយណាស់ សប្បាយចេះតែស្តាប់ដូចថាពេលយើងមានវិប្តតកន្លែងណាទៅថាមិនយំទេ អោយខ្ញុំស្លាប់ចំរៀងយំអីមិនចេះទេ ខ្ញុំមិនលង់ទេ ហើយក៏មិនចេះដែល យើងចេះតែធ្វើអារម្មណ៏នៅក្នុងចិត្តខ្លួនយើងមិនអោយគិតថាពិបាក ហើយខ្ញុំចេះផឹកស្រារ និងចេះលេងស៊ីគូតិចៗដែល អត់កហុកទេរឿភងជិវិត។

កៈ ចារហើយខ្ញុំសុំសួមីងថា មីងមានបងប្អូនណាដែលចេះលេងឧបរកណ៌ភ្លេងខ្មែរឬក៏ភ្លេងសម័យដែលទេមីង?

ខៈ អើថៃខ្ញុំពីដើម គាត់ធ្លាប់លេងល្ខោននិង។

កៈ អរគាត់ជាអ្នកលេងល្ខោន?

ខៈ ចុះឈ្មោះលេងល្ខោនមួយខេត្តស្វាយរៀងនិងនុះ គេស្រលាញ់តួរគាត់ណាស់ថៃខ្ញុំគាត់ស្អាត ហើយឪពុកខ្ញុំក៏ស្អាត ហើយគាត់លេងល្ខោនទៅ ប៉ុន្តែនិស្ស័យពួកខ្ញុំអីក៏ស្រលាញ់ចឹងដែល កាលពីពេលមុននិងគេហៅខ្ញុំទៅច្រៀងភ្លេងការដែលតាស តែខ្ញុំអត់ទៅ ក្រៃលោវាមិនសូវចេះណា នៅក្នុងភូមិវត្តអី គេអោយច្រៀងខាងភ្លេងការនិងណាគេថានាងច្រៀងមិនអៀនចឹងរាំមិនអៀនចឹងអាចលេងបានណា ខ្ញុំថាទេ ខ្ញុំមិនស្អាតទេ គេថាច្រៀងទៅភ្លេងការស្រុកយើងអត់និយាយចឹងទេ។

កៈ ហើយខ្ញុំចង់សួរមីងទៀតថា តើផ្ទះរបស់អ្នកមីងណាតាំងពីរក្មេងរហូតមកដល់អាឡូវមានលក្ខណះមេចដែលមីង?

ខៈ មកចោលផ្ទះ ផ្ទះរុសរោយអស់រលីងហើយគ្មានទេ គ្មានផ្ទះ នៅសល់តែភូមិទេ ខ្ញុំអាឡូវលែងទៅនិងហើយខ្ញុំ ចូលឆ្នាំអីក៏មិនបានទៅ នៅផ្ទះបន្ទាប់ជួលនៅនេះសិន។

កៈ ចារហើយមីងធ្លាប់ជុសជុលនិងសាងសងផ្ទះអីចេះដែលទេមីង?

ខ៖ ចេះ តែចេះធ្វើតែផ្ទះឈើ នៅស្រុកចេះធ្វើទ្រូងជ្រូក ដល់ពេលមានប្ដីចេះធ្វើសំណង់តែម្ដង ពាក្យថាចេះចុះអាឡូវ។

ក៖ ចារហើយមីង ធ្លាប់សាងសង់ផ្ទះខ្លួនឯង ឬក៏ធ្វើអោយគេ?

ខ៖ ទៅធ្វើផ្ទះអោយគេចឹងទៅ ទៅតាមប្ដីធ្វើផ្ទះអោយគេ ជូនកាលគាត់ម៉ៅផ្សេងចឹងទៅទុកអោយយើងមើលរៀនធ្វើទៅ ហៅជាងកម្មករអីនិងរៀនធ្វើទៅ ប៉ុន្តែកាលនិងគាត់ទៅបែកមានស្រីមានអីចឹងទៅ គាត់មិនសូវទុកលុយ ទុកកាក់អីអោយផ្គត់ផ្គង់ពួកយើងទេណា ប៉ុន្តែយើងមិនតូចចិត្តវាសនាខ្លួនឯង បុណ្យយើងបានតិចកាលឆ្នាំនុះ អាឡូវឆ្នាំនេះបានច្រើនជាតិនេះបានច្រើនណាស់តាមផ្លូវបថ្ងៃត្បិតតែក្រទេ ប៉ុនន្តែយើពួកគាត់តាមផ្លូវចាស់ៗអីយើងចូលលុយទិញទឹកសុទ្ធអោយគាត់ហូបចឹង ហើយយើងគាត់អោយពរយើងហើយ តែយើងប្រាថ្នាក្នុងចិត្តថា អោយយើងបានជួបមនុស្សល្អស្អាតមានចិត្តបរិសុទ្ធចឹងណា ដូចថាមានមនុស្សធ្វើអាក្រក់វាតិច តែល្អសុំធ្វើអោយច្រើន ហើយក៏ស្រលាញ់ពួកកូនៗដែល។ ហើយជូនពរអោយកូនឯងសុខសប្បាយរៀនអោយដល់មុខ ហើយអោយចប់បានការងារធ្វើល្អៗ ចារមីងមានតែប៉ុននិង។

ក៖ ចារហើយចង់សួរមីងទៀតថា តើមានជំនាញអីដែលក្រុមគ្រួសារមីងបានបន្សល់ទុកអោយមីងអត់?

ខ៖ ខាងធ្វើនំបញ្ចុកចេះ។

ក៖ អរចេះធ្វើនំបញ្ចុក។

ខ៖ លក់នំបញ្ចុក បុកមន្សៅធ្វើនំបញ្ចុកមិនដែលបានដេកទេ។

ក៖ ចារអានិងឪពុកម្ដាយមីងបង្រៀនមីង?

ខ៖ និងហើយចេះធ្វើអានិង ហើយខ្ញុំចេះឡើងត្នោតទៀត។

ក៖ អរឡើងត្នោតទៀត អ្នកមីងឡើងខ្លួនឯងមែន?

ខ៖ ចារឡើងអាឡូវនិងក៏នៅតែឡើងដែល ទើតែមកភ្នំពេញនិងបានខាន បងខ្ញុំឡើងចឹងចិញ្ចឹមឪពុកម្ដាយបងប្អូន។

កៈ ហើយខ្ញុំសុំសួរមីងទៀតថា តើមីងអាចប្រាប់ខ្ញុំពីពេលដែលមីងលំបាកបំផុតនៅក្នុងជិវិតរបស់មីងនៅពេលណាដែលមីង? តាំងពីតូចមក?

ខៈ នៅពីក្មេងមិនសូវពិបាកប៉ុនន្មានទេនៅជាមួយឪពុកម្តាយចឹងទៅ ដល់នៅតែឪពុកតែពីអ្នកគ្នាយើងវាពិបាកឪកូនចឹងទៅណា ស៊ីឈ្នួលជួយគាត់ ប៉ុន្តែពិបាកជាងគេបំផុតនោះគឺថាបានប្តីមកគាត់មានស្រីនិង យើងក៏មិនដឹងទៅណារកស៊ីអី យើងក៏បែកដំរិះរត់មកនៅភ្នំពេញចឹងទៅណា ខ្ញុំក៏ដើរស៊ីឈ្នួលដឹកអង្ករអោយគេ ជូនការគេអោយអង្ករមកស៊ីចឹងទៅណា ដឹងអោយគេម្តង២០០ជើងអីនុះ ហើយបើឡើងត្នោតស៊ីឈ្នួលកាប់ស្លឹកអោយគេ យកលុយមកធ្វើបបរធ្វើអីអោយកូនស៊ីនិង បើមកភ្នំពេញខ្ញុំមិនដឹង ហើយមានមិនមែនថាអោយធ្លាក់អីទេ យើងចេះតែប្រឹងប្រយ័តខ្លួនឯង ឡើងត្នោតនិងដាច់អស់ហើយជើងដៃ ប៉ុនន្តែមិនដែលអោយធ្លាក់អីទេ។

កៈ ហើយខ្ញុំចង់សួរអ្នកមីងទៀតថា តើអ្នកមីងមានបទពិសោធ៏អ្វីខ្លះដែលល្អៗដែលធ្វើអោយអ្នកមីងមានភាពសប្បាយរីករាយនៅក្នុងជីវិតរបស់អ្នកមីងដែលទេ?

ខៈ អើបទពិសោធ៏ល្អៗនៅក្នុងជិវិតសំរាប់យលងនិងមែន?

កៈ ចារមីង។

ខៈ មានអីខ្ញុំឃើញគេចេះរកស៊ីអីចឹងយើងអរ ឃើញគេរីកចំរើន មិនមែនទៅថាអីអោយគេមីនេះរកស៊ីមានជាងអញនាងអាក្រក់ណាស់ អត់ទេខ្ញុំមិនធ្វើចឹងទេ មានតែបទពិសោធ៏ថាយើងមិនមាននិស្ស័យអីដូចគេទេ យើងធ្វើការដោយកំម្លាំង មិនហ៊ាននេះទេ បុណ្យដោយតែគេមានយើងក្ររកអីបានស៊ី បើគេក្រដែលនាំគ្នាទៅរកអ្នកណា ចឹងខ្ញុំថាគិតថាយើងគិតខ្លីចុះ ព្រោះយើងវាមិនសូវចេះដឹងគិតអីខ្លីៗទៅ។

កៈ ហើយខ្ញុំចង់សួរមីងទៀតថា តើមីងធ្លាប់សង្ឃឹមចង់បានអី ឬក៏ចង់ធ្វើជាគ្រូបង្រៀន ឬក៏ការងារអីដែលទេមីង?

ខៈ ខ្ញុំក៏ធ្លាប់គិតដែលប៉ុន្តែវាវាសនាយើងមិនដល់ មិនទាន់គិតចឹងទេ តែរាល់ថ្ងៃបើនិយាយពីរឿងកូនក៏មិនដាក់ទំនាយអីគាត់ដែល គ្រាន់តែថាអោយកូនរកស៊ីតាមកំម្លាំងដូចពួកខ្ញុំទៅគ្រាន់តែថារកបានមួយថ្ងៃហូបមួយថ្ងៃនិងអោយវា សល់ខ្លះទៅក៏បានធ្វើធំៗទៅក្រៃលោលស់លុយបានទិញដីអីតិចតួចនៅ ទិញដីអីថោកៗទៅណា មិនចង់នៅជួលផ្ទះគេទេ រាល់ថ្ងៃព្រួយបារម្មណ៏ជាងគេតែពេលឈឺទេ ប៉ុនន្តែយើងវាមិនដែលឈឺដែល គ្រាន់តែឈឺខ្យល់កោស

ហើយបាត់ មិនហ៊ានអោយឈឺ មួយឆ្នាំទៅមួយឆ្នាំខ្ញុំមិនដែលស្គាល់ថ្នាំពេទ្យអីនិងគេទេ មិនដែលទេ។

ក៖ ចារល្អណាស់មីង ហើយខ្ញុំសុំសួរមីងទៀតថា បើសិនមីងអាចនិយាយផ្ដែផ្ដាំប្រាប់ទៅកាន់កូនចៅជំនាន់ក្រោយដែលគេបានស្ដាប់លឺអំពីសំលេងមីង តើមីងនិងផ្ដែផ្ដាំប្រាប់អ្វីខ្លះទៅកាន់ពួកគេមីង?

ខ៖ ថាកូនអើយ អោយកូនចៅជំនាន់ក្រោយអោយគាត់រៀនសូត្រអោយបានច្រើនទៅមានមុខរបស់ការងារធូរៗ ចេះគិតនិងគំនិត អានេះកុំតាមពួកខ្ញុំធ្វើការអោយគេនិងកម្លាំង ព្រោះពួកខ្ញុំអត់ចេះអត់បានរៀនសូត្រចេះដឹងអីចឹងគឺទរទេតែម្ដង ចឹងសុំអោយគាត់រកនិងជំរិះនិងគំនិត កុំអោយរកនិងកម្លាំងហាត់ណាស់ ហើយក៏អត់មានសល់ទៀត ចឹងអោយកូនចៅជំនាន់ក្រោយសាលាណាក៏ដោយ សុំអោយលោកគ្រូអ្នកគ្រូ នយោកសាលាអីសុំអោយគាត់ដឹងនាំបានល្អសាលារៀនធំៗសំរាប់កូនចៅ និងកូនចៅខ្ញុំនេះ កូនខ្ញុំមិនបានរៀន ក្រែលោបានចៅអីមានសំណាំបានទៅរៀនចឹងណា ហាហារ។ ហើយខ្ញុំក៏សុំជូនពរដល់នយោកសាលា ដល់គ្រូនិងបងប្អូនកូនចៅអីទាំងអស់និងណាមួយក្រុម សាលាណាក៏ដោយ យើងមិនដឹងថាមានសាលាណាខ្លះទេណា គឺសូមអោយអ្នកគ្រូបង្រៀនសុខសប្បាយមានសុខភាពល្អនិងអាយុវែងទាំងអស់គ្នាហើយអោយដល់នយោកសាលាទាំងអស់គ្នាផងគ្រប់គ្រូទាំងអស់ ហើយអោយដល់កូនពៅផងនិងក្រុមបុគ្គលិតធ្វើការងារទាំងអស់និង សុំអោយសុខសប្បាយ ហើយអោយមានសំណាងល្អនិងជូនពរជាងគែ គឺសំណាងល្អនិង បើយើងមានសំណាងទើបមានល្អណា ត្រូវដែរ សុំអោយសុខសប្បាយណាពៅណាស់។ សំភាស៏រួចហើយចាំទៅនុះហូបស្វាយ នៅខាងក្រោយមានស្វាយមានអី ហើយសុំជូនពរអោយកូនឯងទៅសុខសប្បាយតាមផ្លូវ មានតែប៉ុននិងជូនពររហូត ហាហារ។

ក៖ អរគុណមីង ហើយអរគុណមីងដែលផ្ដល់ឧកាសអោយខ្ញុំធ្វើការសំភាស៏មីង៕